**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ :....០៦....សសរ

# សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការអភិវឌ្ឍន៍តំបន់កសិ-ទេសចរណ៍ វប្បធម៌ នៃអតីតព្រះបរមរាជវាំងចាស់ "ល្វែងព្រះស្តេចកន" ស្ថិតក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៦៩៩ / ០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

## ស ំ រេ ច

**ប្រការ ១ :** សមាសភាពគណៈកម្មការអភិវឌ្ឍន៍តំបន់កសិ-ទេសចរណ៍ វប្បធម៌ នៃអតីតព្រះបរមរាជវាំងចាស់ **"ល្វែងព្រះស្តេចកន"** មានរាយនាមដូចតទៅ :

១- ឯកឧត្តម **លឹម គានហោ** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ប្រធាន

២- ឯកឧត្តម **នុត ណារ៉ង** រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុប្រធាន

| | | | |
|---|---|---|---|
| ៣- ឯកឧត្តម | **ជុំច គឿន** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |
| ៤- ឯកឧត្តម | **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រី ក្រសួងព័ត៌មាន | សមាជិក |
| ៥- ឯកឧត្តម | **អ៊ុក រ៉ាប៊ុន** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- ឯកឧត្តម | **ថោង ខុន** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៧- ឯកឧត្តម | **តេង ឡៅ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨- ឯកឧត្តម | **សាត សាមី** | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- ឯកឧត្តម | **ហ៊ុន ណេង** | អភិបាលខេត្តកំពង់ចាម | សមាជិក |
| ១០- ឯកឧត្តម | **អ៊ុង សាមី** | អភិបាលខេត្តព្រៃវែង | សមាជិក |
| ១១- លោកឧកញ៉ា | **ស៊ឹម ចណ្ណា** | អគ្គនាយកចំការកៅស៊ូបឹងកេត | សមាជិក |
| ១២- លោក | **ស៊ុន សុខលី** | អភិបាលស្រុកពញាក្រែក | សមាជិក |
| ១៣- លោក | **ស៊ឹម ស៊ីថុច** | អភិបាលស្រុកត្បូងឃ្មុំ | សមាជិក |
| ១៤- លោក | **ឃុន ថា** | អភិបាលស្រុកអូររាំងឪ | សមាជិក |

**ប្រការ ២ :** គណៈកម្មការនេះ មានភារកិច្ចរៀបចំអភិវឌ្ឍន៍តំបន់ នៃអតីតព្រះបរមរាជវាំងចាស់ "**ឃ្លាំងព្រះស្តេចកន**" ស្ថិតក្នុងឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ឱ្យក្លាយជាតំបន់កសិ-ទេសចរណ៍ វប្បធម៌ ។

**ប្រការ ៣ :** សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១, ខែ ០២ ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ